ដកស្រង់ចេញពីសៀវភៅៈ

## មេខ្មោងសួរចម្លើយ ៖ ការក្លាយជាអ្នកធ្វើទារុណកម្មរបស់ខ្មែរក្រហម[១]

*ធេរី ក្រូវែលលីយេ*

*កាលពីឆ្នាំ២០០៩ អ្នកសារព័ត៌មានឈ្មោះ ធេរី ក្រូវែលលីយេ បានចូលរួមស្តាប់ការកាត់ទោស និងការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ក្នុងសំណុំរឿង កាំង ហ្គេចអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ របស់ខ្មែរក្រហម ។ នៅថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្តន្ទាទោស ឌុច ឲ្យជាប់ពន្ធនាគាររយៈពេល៣៥ឆ្នាំ[២] អំពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម[៣] ។ បន្ទាប់មកនៅដំណាក់កាលអង្គជំនុំជម្រះតុលាការកំពូល អង្គជំនុំជម្រះតុលាការកំពូលបានរក*

---

[១] បោះពុម្ពផ្សាយដោយ Gallimard នៅក្នុងប្រទេសបារាំង ឆ្នាំ២០១១ មានចំណងជើងថា LE MAÍTRE DES AVEUX បកប្រែជាភាសាអង់គ្លេសដោយ Alex Gilly និងបានបោះពុម្ពផ្សាយដោយសារព័ត៌មាន Ecco ក្នុងខែមីនា ឆ្នាំ២០១៤ ។ អត្ថបទដកស្រង់ត្រូវបានបោះពុម្ពផ្សាយម្តងទៀតដោយមានការអនុញ្ញាតពីអ្នកនិពន្ធ *ធេរី ក្រូវែលលីវេ,* Susanna Lea Associates និងអ្នកបោះពុម្ពផ្សាយ Harper Collins ។

[២] ដូចខាងលើ ។ សូមមើលកថាខណ្ឌ ៦២៨ ដល់៦៣១ (ការបន្ធូរបន្ថយទោសរបស់ ឌុច ត្រូវបានទទួលស្គាល់ ដែលមានចំណុចរួមបញ្ចូលដូចជា “ការទទួលខុសត្រូវ ការបង្ហាញវិប្បដិសារី.....ស្ថានការដែលគាត់បានគ្រប់គ្រងនៅក្នុង(របបកម្ពុជាប្រជាធិបតេយ្យ) និងសក្តានុពលក្នុងការកែខ្លួនរបស់គាត់”) ។ ការកាត់ទោសរបស់ ឌុច ត្រូវបានបន្ធូរបន្ថយចំនួន៥ ឆ្នាំជាសំណងចំពោះការឃុំខ្លួនមិនស្របច្បាប់ដោយតុលាការយោធាកម្ពុជា មុនពេលគេបញ្ជូនគាត់មកកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអស់រយៈពេលជិត១១ឆ្នាំ ដែលគាត់ត្រូវបានឃុំខ្លួនដោយរដ្ឋាភិបាលកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៩ ។ សូមមើលផងដែរ កថាខណ្ឌ ៦២៣ដល់៦២៧ និងកថាខណ្ឌ៦៣២ដល់៦៣៣ ។

[៣] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានរកឃើញពីការទទួលខុសត្រូវរបស់ ឌុច ចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រាប់បញ្ចូលទាំង បទរំលោភសេពសន្ថវៈ) ការរើសអើងដោយសារហេតុផលនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ហើយនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ មានដូចជាការមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាប

ឃើញថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងមិនបានឆ្លុះបញ្ចាំងនូវបទឧក្រិដ្ឋធ្ងន់ធ្ងរដែល ឌុច បានប្រព្រឹត្តនៅឡើយទេ ហេតុដូច្នេះ តុលាការកំពូលបានសម្រេចបន្ថែមកម្រិតទោស ដោយសម្រេចផ្តន្ទាទោស ឌុច ឲ្យជាប់ពន្ធនាគារអស់មួយជីវិត[៤] ។

## ជំពូក៦

ឌុច ក្រោកឈរហើយគោរពអង្គតុលាការ ។ គាត់ចាប់ផ្តើមដោយនិយាយថា សេចក្តីវេទនារបស់ប្រជាជនគាត់បានចាប់ផ្តើមតាំងពីជំនាន់រាជរដ្ឋាភិបាលគាបសង្កត់របស់ សម្តេច សីហនុ នៅពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៦០មកម្ល៉េះ ហើយការគាបសង្កត់នេះបានបន្តរហូតដល់ការធ្វើរដ្ឋប្រហារពីសំណាក់ពួកស្តាំនិយមនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ។ នៅពេលនោះ «គ្រប់ភាគីទាំងអស់ប្រឡូកប្រជែងគ្នាសម្លាប់ប្រជាពលរដ្ឋកម្ពុជារហូតដល់ឆ្នាំ១៩៧៥» ។ ដៃម្ខាងរបស់គាត់កាន់ក្រដាសមួយសន្លឹក ហើយដៃម្ខាងទៀតទ្រោបលើចុងតុ ។ ក្នុងរយៈពេលប៉ុន្មាននាទីតែប៉ុណ្ណោះ សវនាការមានសភាពស្ងប់ស្ងាត់ ។ ទោះបីជាសវនាការបានចាប់ផ្តើមដំណើរការតាំងពីយូរហើយក៏ដោយ ប៉ុន្តែបរិយាកាសនៅក្នុងបន្ទប់តុលាការទើបតែផ្លាស់ប្តូរក្នុងពេលនេះ ព្រោះវាគឺជាដំណាក់កាលមួយដ៏សំខាន់ ។ ឌុច កំពុងធ្វើការសុំអភ័យទោស:

> គ្មានរូបភាពណាមួយអាចបង្ហាញអំពីវិប្បដិសារី និងទុក្ខសោករបស់ខ្ញុំបានឡើយ ។ ខ្ញុំមានការឈឺចាប់ជាពន់ពេក ហើយខ្ញុំមិនអាចបំភ្លេចបាននោះទេ ។ ខ្ញុំតែងតែនិយាយដដែលៗថា ការសម្រេចចិត្តខុសក្នុងមួយប៉ប្រិចភ្នែកអាចនាំមកនូវការឈឺចាប់ និងវិប្បដិសារីអស់មួយជីវិត ។ ខ្ញុំយល់ព្រមតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះនេះចំពោះបទឧក្រិដ្ឋ

---

ដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិល នូវសិទ្ធិទទួលបានការកាត់ទោស ដោយយុត្តិធម៌និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ។ សូមមើល សាលក្រមសំណុំរឿង០០១ កថាខណ្ឌ៥៥៩ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ។

[៤] សូមមើល សាលដីកាសំណុំរឿង០០១ កថាខណ្ឌ៣៨៣ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ។

ដែលខ្ញុំបានប្រព្រឹត្ត ។ ខ្ញុំមិនបន្ទោសថ្នាក់លើរបស់ខ្ញុំទេ ហើយខ្ញុំក៏មិនស្តីបន្ទោសថ្នាក់ក្រោមរបស់ខ្ញុំដែរ ។ ខ្ញុំមិនគេចវេសពីទំនួលខុសត្រូវរបស់ខ្ញុំឡើយ ។ ទោះបីជាបទឧក្រិដ្ឋទាំងអស់ដែលបានប្រព្រឹត្តឡើងក្រោមការបញ្ជារបស់ថ្នាក់លើក៏ដោយ ប៉ុន្តែអ្វីទាំងអស់នៅតែធ្វើឡើងក្នុងវង្វង់សមត្ថកិច្ចមន្ទីរស-២១របស់ខ្ញុំដដែល ។ បើផ្អែកលើចិត្តសាស្ត្រនិងមនោគមវិជ្ជា ខ្ញុំមានទំនួលខុសត្រូវចំពោះរឿងអ្វីៗដែលបានកើតឡើង ។ ខ្ញុំអនុវត្តគោលនយោបាយបក្ស ប៉ុន្តែខ្ញុំមានការស្តាយក្រោយរាល់ទង្វើដែលខ្ញុំបានធ្វើ ។

ប៊ូ ម៉េង (អ្នករស់រានមានជីវិតពីមន្ទីរស-២១) ផង់ក្បាលយល់ព្រម ។ ឌុច មើលទៅហាក់បីដូចជាកំពុងតែញាក់ញ័រ ។ ចៅក្រមស៊ើរតែមិនក្រលេកមើលទៅគាត់ ។ ឌុច បានដកវ៉ែនតាចេញ និងទ្រាបដៃទាំងពីរលើតុ ។ ឌុច មើលមនុស្សជុំវិញខ្លួនគាត់ម្តងម្នាក់ៗ ហើយក៏ចាប់ផ្តើមនិយាយទៅកាន់ព្រះរាជអាជ្ញា ។

ឌុច បាននិយាយថា "ខ្ញុំមិនដែលចូលចិត្តការងាររបស់ខ្ញុំទេ"

ឌុច បានដកដង្ហើមធំ នៅពេលរៀបរាប់ពីការចាប់ខ្លួនរបស់គាត់កាលពីខែឧសភា ឆ្នាំ១៩៩៩ ។ នៅទីបំផុត គាត់ធ្វើការបរិយាយអំពីក្រដាសដែលគាត់កាន់ជាប់នឹងដៃចាប់តាំងពីពេលបើកសវនាការមក ។ គាត់និយាយថាវាគឺជារូបគំនូរដែលគាត់បានគូរដោយផ្ទាល់ដៃ ហើយគាត់ចង់បង្ហាញរូបនេះទៅកាន់ចៅក្រម ។ គាត់ក៏អង្គុយចុះវិញ ពេលដែលរង់ចាំការអនុញ្ញាតពីតុលាការ ។ ប្រជាពលរដ្ឋទាំងអស់គ្នាបានរង់ចាំអស់រយៈ៣០ឆ្នាំ ដើម្បីស្តាប់នូវអ្វីដែល ឌុច បាននិយាយដើម្បីការពារខ្លួនរបស់គាត់ ។ នៅកន្លែងអង្គុយសម្រាប់សាធារណជនមានការនិយាយខ្សឹបខ្សៀវគ្នាតិចៗ ប៉ុន្តែពុំឃើញមាននរណាបង្ហាញអំពីអារម្មណ៍អ្វីទាំងអស់នៅពេលនោះ ។

ឌុច ព្យាយាមពន្យល់ពីលក្ខណៈពិសេសនៃគំនូរនេះ ។ គាត់ចង្អុលបង្ហាញរូបគំនូរកៅអីបីដែលមាននៅក្នុងលើក្រដាស ដោយចាប់ផ្តើមនិយាយថា នោះគឺជាតួនាទី និងមុខងាររបស់ ប៉ុល ពត នួន ជា និង តា ម៉ុក ដែលពួកគេគឺជា បងធំទី១ ទី២ និង ទី៤ នៃថ្នាក់ដឹកនាំខ្មែរក្រហម ។ បន្ទាប់មកទៀត ឌុច ពន្យល់ថា

អៀង សារី គឺជាអ្នករៀបចំរចនាសម្ព័ន្ធក្នុងបក្សកុម្មុយនីស្តកម្ពុជាជាមួយបងធំទាំងបីនាក់នេះ ។ លោកប្រធានចៅក្រមបានផ្តោតអារម្មណ៍ទៅកាន់ចុងចោទ រីឯចៅក្រមដទៃទៀតងាកមើលអ្វីផ្សេងវិញ ។ ការចាប់ផ្តើមរបស់ជនជាប់ចោទ ឌុច ទៅកាន់អង្គតុលាការ គឺមានភាពរន្ថោះរន្ធើ ។

បន្ទាប់ពីការមកដល់ភ្នំពេញនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៥ ឌុច ក៏ដូចជាកម្មាភិបាលខ្មែរក្រហមដទៃទៀត បានចូលរួមវគ្គបណ្តុះបណ្តាលផ្នែកនយោបាយរយៈពេលពីពីរទៅបីថ្ងៃ ។ គាត់បាននិយាយជាភាសាបារាំងថា “គាត់ត្រូវបានគេបង្រៀនអំពីទស្សនៈនៃការធ្វើបដិវត្តន៍នៅក្នុងពិភពលោក” ។ សមមិត្តនីមួយៗត្រូវសរសេរអំពីប្រវត្តិរូប និងមនោគមវិជ្ជារបស់ខ្លួន ។ ការប្រារព្ធពិធី “ជ័យជម្នះដ៏មហាអស្ចារ្យថ្ងៃទី១៧ មេសា” ដែលជាថ្ងៃដែលបក្សកុម្មុយនីស្តដណ្តើមយកបានទីក្រុងភ្នំពេញ គឺជាប្រធានបទសំខាន់ ។ ការបេ្តជ្ញាចិត្តត្រូវធ្វើឡើង ដោយការសរសេរអំពីគុណសម្បត្តិនៃសមូហភាព ការបង្រៀនអំពីលទ្ធិសង្គមនិយម និងការបន្តធ្វើបដិវត្តន៍ ។ សមមិត្តម្នាក់ៗ បន្ទាប់ពីសរសេរជីវប្រវត្តិ និងការបេ្តជ្ញាចិត្តរបស់ខ្លួនរួចហើយ ពួកគេត្រូវអានឲ្យសមមិត្តដទៃទៀតស្តាប់ ហើយសមមិត្តទាំងនោះអាចសួរសំណួរបាន ។ គ្រប់គ្នាត្រូវលាតត្រដាងពីជីវប្រវត្តិគ្រួសាររបស់ខ្លួន ហើយការលាតត្រដាងនោះគឺមានគ្រោះថ្នាក់ណាស់ ពីព្រោះជនណាដែលមានញាតិសន្តានមិនល្អអាចនឹងត្រូវយកទៅសម្លាប់ ។ ឌុច មិនបានបញ្ជាក់ថា គាត់មានជាប់សាច់ឈាមជាមួយក្មួយស្រីរបស់ លន់ នល់ ដែលជាសេនាប្រមុខម្នាក់កំពុងតែត្រូវបានរកចាប់ខ្លួននោះទេ ។ ឌុច បាននិយាយថា គ្រានោះហើយដែលគាត់ខិតខំព្យាយាមចាកចេញពីការទទួលខុសត្រូវផ្នែកសន្តិសុខរបស់បក្សដែលគាត់បានបម្រើការអស់រយៈពេលបួនឆ្នាំមកហើយនោះ ។ ឌុច បានបន្តទៀតថា គាត់បានស្នើសុំថ្នាក់លើរបស់ខ្លួនដើម្បីប្តូរទៅធ្វើការនៅក្រសួងឧស្សាហកម្មវិញ ។ នៅពេលចៅក្រមសុំឲ្យ ឌុច ធ្វើការបកស្រាយលម្អិត គាត់ក៏ឆ្លើយតបជាសុភាសិតមួយដែលចៅក្រម ជាពិសេសចៅក្រមបរទេសអាចបកស្រាយតាមចិត្តបាន ។ សុភាសិតនោះគឺ “តើវាចាំបាច់ឬទេដែល យើងត្រូវបំបែកសំបកក្តាម ដើម្បីមើលសភាពខាងក្នុងរបស់វា?”

នៅពេលចៅក្រមសួរគាត់ថា តើគាត់នៅតែពេញចិត្តការងារសន្តិសុខនេះដែរឬទេ ប្រសិនជាគាត់មិនដឹងថា រាល់អាថ៌កំបាំង និងអំណាចនៅក្នុងរចនាសម្ពន្ធ័របស់បក្សអស្ចារ្យ? ឌុច មិនមានចម្លើយត្រឹមត្រូវសម្រាប់សំណួរនេះទេ ។ ចៅក្រមទទូចចង់ឲ្យ ឌុច ឆ្លើយតបសំណួរនេះ តែ ឌុច ព្យាយាមមិនឆ្លើយ ។ ពេលដែលចៅក្រមនៅតែទាមទារឲ្យ ឌុច ឆ្លើយ គាត់ផ្តល់តែចម្លើយដដែល ហើយនៅពេលសួរបន្ថែមទៀត ឌុច បានពន្យល់ថា មនសិការរបស់គាត់បានយល់ស្របថា ការងាររបស់គាត់ គឺសាហាវឃោរឃៅ ឬមួយថាចម្លើយសារភាពភាគច្រើន គឺជាចម្លើយដែលពុំមានការពិត ។ យ៉ាងណាមិញ សំណួរដែលពិបាកនឹងឆ្លើយថាតើគាត់ពេញចិត្តនឹងការចូលរួមប្រព្រឹត្តបទឧក្រិដ្ឋដែរឬយ៉ាងណា? មិនបានឃ្លាតទៅណាឆ្ងាយពីការសួររបស់ចៅក្រមឡើយ ហើយនៅទីបំផុត ឌុច បានខំព្យាយាមឆ្លើយតបនឹងសំណួរទាំងអស់នោះ ។

ការខំប្រឹងប្រែងរបស់គាត់បានទទួលបរាជ័យ ។

គាត់និយាយថា “ខ្ញុំគ្រាន់តែជាឧបករណ៍ដែលគេប្រើប្រាស់នៅក្នុងបក្ស ជាឧបករណ៍ដើម្បីពង្រឹងអំណាចរបស់គេប៉ុណ្ណោះ” ។

**អក្សរ ស ដែលមាននៅក្នុងមន្ទីរស-២១** គឺពាក្យកាត់សម្រាប់សន្តិបាល ។

នៅក្នុងសទ្ទានុក្រមរបស់ពុទ្ធសាសនិក ពាក្យសន្តិបាល មានន័យថា ជាក្រុមមនុស្សដែលថែរក្សាសន្តិភាព និងស្ថេរភាព ដូចជាប៉ូលីស ។ នៅក្រោមរបប ប៉ុល ពត ពាក្យ សន្តិបាល គឺជាឈ្មោះដែលត្រូវបានប្រើសម្រាប់កំណត់អំពីប្រពន្ធ័សន្តិសុខផ្ទៃក្នុង ហើយនៅក្នុងរបបកុម្មុយនីស្ត ពាក្យសន្តិបាល ជាទូទៅសំដៅទៅលើនគរបាលសន្តិសុខ(ប៉ូលីស) សម្ងាត់ ។ នៅចុងខែមីនា ឆ្នាំ១៩៧៥ សុន សេន ដែលជាប្រធានសន្តិសុខរដ្ឋ និងជារដ្ឋមន្ត្រីការពារជាតិ បានប្រាប់ ឌុច ថា មន្ទីរឃុំឃាំង និងអគ្គភាពស៊ើបការណ៍ត្រូវបានបង្កើតឡើងនៅក្នុងទីក្រុងភ្នំពេញ ។ គាត់បានប្រាប់ ឌុច ថា មន្ទីរឃុំឃាំង និងមណ្ឌលស៊ើបការណ៍ទាំងនោះយកគំរូតាម “ប្រតិចារកិច្ច” របស់ប្រទេសបារាំង ។

បើយោងតាមការរៀបរាប់របស់ ឌុច លេខ«២១» នៅក្នុងមន្ទីរស-២១ គឺជាលេខកូដវិទ្យុបង្កើតឡើងដោយ ណាត ដែលជាប្រធានទីមួយនៃមន្ទីរសន្តិសុខមួយនេះ ។

ឌុច ទទួលបញ្ជាឲ្យទៅឆែកឆេរអគាររបស់រដ្ឋាភិបាល និងផ្ទះរបស់មន្ត្រីរាជការក្នុងរបបចាស់ ។ គាត់បានប្រមែប្រមូល និងរៀបចំរបាយការណ៍ រួមទាំងឯកសារសំខាន់របស់របបមុនដែលបានដួលរលំ ។ នៅទីស្នាក់ការកណ្តាលរបស់មន្ត្រីនគរបាលយុត្តិធម៌ គាត់បានយកឯកសារដែលទាក់ទងនឹងការធ្វើទារុណកម្ម ។ មន្ទីរស-២១ ត្រូវបានបង្កើតឡើងនៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ ដែលមាន ណាត ជាប្រធាន ហើយ ឌុច ជាអនុប្រធាននៅពេលនោះ ។

មន្ទីរនេះត្រូវបានបង្កើតឡើងដំបូងគេបង្អស់ ដើម្បីលុបបំបាត់ចោលប្រពន្ធ័នយោបាយមូលធននិយម-សក្តិភូមិនិយម ។ ជនដែលបម្រើឲ្យរបបនយោបាយនេះមានដូចជា កងកំលាំងទាហាន អ្នករាជការក្នុងរបបចាស់ វណ្ណៈអភិជន ប្រជាជនថ្មី ដែលនៅតែដើមតាមរបបចាស់ និងអ្នករស់នៅទីក្រុង ។ បដិវត្តន៍យល់ថា ការទុកអ្នកមានជំងឺសតិអារម្មណ៍ពុំមានចំណេញអ្វីទេ ។ ពីដំបូងឡើយ មន្ទីរស-២១ ក៏ត្រូវបានប្រើប្រាស់ជាមន្ទីរពេទ្យព្យាបាលមនុស្សវិកលចរិតដែរ ។ តើមានរឿងអ្វីកើតឡើងចំពោះអ្នកជំងឺផ្លូវចិត្តនៅមន្ទីរស-២១?

«ផ្អែកតាមការវិភាគផ្ទាល់ខ្លួនរបស់ខ្ញុំ ទោះបីជាខ្ញុំមិនដឹងច្បាស់ក៏ដោយ ប៉ុន្តែខ្ញុំអាចនិយាយបានថាច្រើនជាង៥០ភាគរយនៃអ្នកជំងឺទាំងអស់ត្រូវបានកម្ទេចចោល[៥]» ឌុច បានលើកឡើងដូច្នេះ ។

[៥] «កម្ទេចចោល» គឺត្រូវបានបកប្រែជាភាសាអង់គ្លេសផ្លូវការ និងប្រើប្រាស់ក្នុងតុលាការ ដែលមានន័យថា ការសម្លាប់ប្រជាពលរដ្ឋ ឬការសម្លាប់ផុតពូជ ។

គាត់មានការចងចាំល្អនូវអ្វីដែលថ្នាក់លើបញ្ជាឲ្យគាត់ធ្វើទៅកាន់អ្នកជំងឺឃ្លង់ ៖ កម្ទេចពួកគេចោលអោយអស់ទៅ ។ លទ្ធិកុម្មុយនីស្តត្រូវតែរំដោះមនុស្សជាតិទាំងមូល ។ ប៉ុន្តែ លទ្ធិកុម្មុយនីស្តនិយមស្អប់ខ្ពើមបំផុតមនុស្សពិការ វិកលចរិត សាសនា មនុស្សស្រលាញ់ភេទដូចគ្នា និងបញ្ញវន្ត ។

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ថ្នាក់ដឹកនាំរបស់បក្សបានចុះហត្ថលេខាលើការបញ្ជាជាសម្ងាត់ដើម្បីធ្វើបន្សុទ្ធកម្មនៅក្នុងជួរបក្សរបស់ខ្លួន ។ ការធ្វើបន្សុទ្ធកម្មនេះគឺជាចំណុចរបត់មួយ ពីព្រោះវាជាភ័ស្តុតាងជាក់ស្តែងបង្ហាញអំពីគោលការណ៍សម្លាប់រង្គាល ដែលអនុវត្តន៍ដោយអង្គការសម្ងាត់ ។ ការបញ្ជានេះបានធ្វើឲ្យការសម្លាប់ដែលបានអនុវត្តខ្លះរួមមកហើយដោយគណៈកម្មាធិការតំបន់ គណៈកម្មាធិការកណ្តាល និងកងកំលាំងយោធា ឲ្យទៅជាគោលនយោបាយតែម្តង ។ ដូច្នេះ ការធ្វើបន្សុទ្ធកម្មបានចាប់ផ្តើមពីក្រសួងមួយទៅក្រសួងមួយ ពីកងមួយទៅកងមួយ និងពីតំបន់មួយទៅតំបន់មួយទៀត ។ ណាត បាត់បង់ការងារ តែឌុច បានឡើងតំណែងជាប្រធាន ហើយមន្ទីរស-២១ចាប់ផ្តើមមានបេសកម្មថ្មី ។ បេសកកម្មថ្មីនេះ គឺផ្តោតសំខាន់ទៅលើការបោសសម្អាតខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ដោយយោងទៅតាមការបញ្ជាពីថ្ងៃទី៣០ ខែមីនា ប៉ុន្តែឌុច ខ្លួនឯងផ្ទាល់ពុំបានដឹងថាមានការបញ្ជាបែបនេះឡើយ ។ ឌុច ទើបតែដឹងអំពីការសម្រេចចិត្តរបស់អង្គការឲ្យមានការបោសសម្អាតនេះ ៣០ឆ្នាំក្រោយ នៅពេលគាត់ជាប់ឃុំឃាំងក្នុងពន្ធនាគារ ។

ចៅក្រមឡាវែន់បានសួរទៅកាន់ ឌុច ថា «ហេតុអ្វីបានជាលោកត្រូវបានជ្រើសរើសឲ្យគ្រប់គ្រងមន្ទីរស-២១?»

> *វាជាការពិត ដំបូងឡើយ ខ្ញុំជាអ្នកសួរចម្លើយល្អជាង ណាត ។ ប៉ុន្តែនេះមិនមែនជាមូលហេតុតែមួយគត់នោះទេ ។ បក្សមិនមានទំនុកចិត្តលើ ណាត នោះទេ ។ សុនសេន ធ្លាប់និយាយប្រាប់ខ្ញុំថា របៀបគ្រប់គ្រងរបស់ ណាត មើលទៅហាក់បីដូចជាគួរឲ្យសង្ស័យ ។ ណាត អាចជាជនក្បត់ ។ ប៉ុន្តែ ខ្ញុំវិញ គឺស្មោះត្រង់ ខ្ញុំសុខចិត្តស្លាប់ជាជាងនិយាយកុហកសមាជិកបក្ស ។ ខ្ញុំរាយការណ៍គ្រប់រឿងដែលខ្ញុំបានដឹង ។ ខ្ញុំតែង*

*តែធ្វើការងាររបស់ខ្ញុំតាមវិធីសាស្ត្រត្រឹមត្រូវ ។ ក្នុងមួយជីវិតរបស់ខ្ញុំ គ្រប់ពេលដែល ខ្ញុំធ្វើអ្វីមួយ គឺខ្ញុំធ្វើវាដោយហ្មត់ចត់ ។*

ឌុច បានអះអាងថា ខ្លួនមានការភ័យខ្លាច នៅពេលឡើងមកគ្រប់គ្រងមន្ទីរស-២១ ។ គាត់ បាននិយាយថា គាត់ធ្លាប់បានស្នើសុំឲ្យនរណាម្នាក់ផ្សេងមកជំនួសតំណែងនេះ ប៉ុន្តែ សុន សេន បានគំរាមគាត់ ។ នៅពេលដែល ឌុច ព្យាយាមឆ្លើយតបចំពោះមុខអង្គជំនុំជម្រះ គាត់បានតំឡើងសំឡេងរហូតដល់ការនិយាយភាសាខ្មែររបស់គាត់ស្តាប់ទៅឡើងញ័រ ។

គាត់និយាយថា "ខ្ញុំគ្រាន់តែជាឆ្កែដែលគេបង្ហាត់ឲ្យមើលចៀម" ។

ប៉ុន្តែ ព្រះរាជអាជ្ញាយល់ថា ឌុច គឺជាមនុស្សសាហាវសមបំផុតចំពោះការងារនេះ ។

ប្រវត្តិវិទូម្នាក់ ដែលមានឈ្មោះថា ដេវីដ ឆេនដល័រ (David Chandler) តែងតែនិយាយ ថា មន្ទីរស-២១ អាចជាស្ថាប័នដែលមានឥទ្ធិពលខ្លាំងជាងគេនៅក្នុងប្រទេសកម្ពុជាក្រោមរបបសាហាវឃោរឃៅខ្មែរក្រហម ដែលប្រកាន់យកលទ្ធិម៉ៅនិយម ។ ឯកសារមន្ទីរសន្តិសុខ ដែលនៅសេសសល់ទាំងអស់នេះ បានបង្ហាញថា មន្ទីរស-២១ មានប្រសិទ្ធភាពទំនើប ហើយមានជំនាញច្បាស់លាស់ ។ ព័ត៌មានទាំងអស់នៅក្នុងឯកសារត្រូវធ្វើឲ្យថ្នាក់ដឹកនាំបក្សជឿជាក់ថា ជនសង្ស័យទាំងអស់របស់បក្សត្រូវបានរកឃើញ ។ ឯកសារទាំងអស់នោះបានធ្វើឲ្យបក្សមានការពេញចិត្តពីព្រោះវាបង្ហាញថាបក្សបានកម្ចាត់សត្រូវអស់ហើយ ដូច្នេះបក្សកំពុងទទួលបានជ័យជម្នះកាន់តែខ្លាំង ទោះបីជាសត្រូវថ្មីជាច្រើនត្រូវបានរកឃើញទៀត ។

លោក ឆេនដល័រ មិនគិតថាខ្មែរក្រហមអនុវត្តតាមគោលការណ៍លទ្ធិកុម្មុយនិស្តមួយណាច្បាស់លាស់នោះទេ ។ មន្ទីរសន្តិសុខស្រដៀងគ្នាទៅនឹងមន្ទីរស-២១ នៅក្នុងរបបខ្មែរក្រហមធ្លាប់មាននៅក្នុងប្រទេសចិន និងសហភាពសូវៀត មន្ទីរទាំងនោះ គឺជាទីកន្លែងធ្វើទារុណកម្ម សួរចម្លើយសារភាព ឬ "ជាកន្លែងអប់រំកែប្រែ" ។ បដិវត្តន៍រុស្ស៊ីរបស់ លេនីន វិនាសអន្តរាយដោយសារការធ្វើបន្សុទ្ធកម្ម ។ អ្វីដែល លោក

ឆេនល័រ ជឿជាក់ថាជាចំណុចគួរឲ្យកត់សម្គាល់បំផុតរបស់មន្ទីរស-២១នោះ គឺភាពអាថ៌កំបាំងរបស់មន្ទីរសន្តិសុខមួយនេះ ។ គាត់បាននិយាយថា ការដែលឲ្យអ្នកទោស "រៀនសូត្រឡើងវិញ" បន្ទាប់មកសម្លាប់ពួកគេ គឺជាអ្វីមួយមិនធ្លាប់មានពីមុនមក ។ ការសម្លាប់ជាប្រព័ន្ធដែលបានកើតមានឡើងនៅមន្ទីរស-២១ ធ្វើឲ្យមន្ទីរសន្តិសុខនេះក្លាយទៅជាគុកសម្ងាត់ និងទីពិឃាតដែលមានលក្ខណៈខុសប្លែកពីមន្ទីរសន្តិសុខដទៃទៀត ។

គុក និងមន្ទីរសួរចម្លើយជាច្រើនមានពាសពេញប្រទេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយកន្លែងទាំងនោះ គឺជាទីដែលភ្នាក់ងារឈ្លុតខ្មៅប្រព្រឹត្តអំពើហិង្សាទៅលើអ្នកទោស ។ ប៉ុន្តែ គុក និងមន្ទីរទាំងអស់នេះពុំមានទំនាក់ទំនងនឹងគ្នានោះទេ ។ មន្ទីរស-២១មិនមានសិទ្ធិអំណាចស្វ័យភាព ឬអាចទាក់ទងដោយផ្ទាល់ជាមួយគុកដទៃទៀតនោះទេ ហើយរាល់គ្រប់ភារកិច្ចទាំងអស់ត្រូវឆ្លងកាត់ "មជ្ឈិម" ។ មន្ទីរស-២១ មានលក្ខណៈប្លែកពីគុកដទៃទៀតនៅត្រង់ថា មន្ទីរនេះមានដែនសមត្ថកិច្ចពាសពេញប្រទេស ពីព្រោះមន្ទីរស-២១ អាចទទួលយកអ្នកទោសពីគ្រប់ទីកន្លែង និងមានទំនាក់ទំនងដោយផ្ទាល់ជាមួយ "ថ្នាក់លើ" ។ មន្ទីរស-២១ ជាផ្នែកមួយរបស់សន្តិបាល ដែលជាភ្នាក់ងារផ្សារភ្ជាប់ទៅនឹងអំណាចកណ្តាល គឺគណៈអចិន្ត្រៃយ៍ដែលជាអង្គការពិតប្រាកដ ដែលមានចំនួនសមាជិកប្រាំ ឬប្រាំពីររូប ។ មន្ទីរស-២១ គឺជាឧបករណ៍ពិសេសផ្តាច់មុខរបស់អង្គការ ។ អ្នកទោសសំខាន់ៗ ដូចជា អតីតសមាជិកនៃគណៈមជ្ឈិម ឬអ្នកដែលមានតំណែងខ្ពស់នៅជួរបក្ស ត្រូវបានបញ្ជូនមកមន្ទីរស-២១ មិនមែនគុកដទៃនោះទេ ។

ចំណុចគួរឲ្យកត់សម្គាល់មួយទៀតរបស់មន្ទីរស-២១ គឺមន្ទីរសន្តិសុខមួយនេះបានបង្កើតនូវកន្លែងផ្ទុកឯកសារផ្ទាល់ខ្លួន ។ គ្មានគុកណានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបានគ្រប់គ្រងល្អឥតខ្ចោះ និងមានបទពិសោធន៍ដូចមន្ទីរសន្តិសុខនេះទេ ។ ប៉ុន្តែ គ្មានគុកដទៃណានៅក្នុងប្រទេសកម្ពុជា អាចរក្សាបានឯកសារទាំងអស់ដោយគ្មានខូចខាតនោះទេ ។ យើងដឹងតិចតួចណាស់អំពីមន្ទីរសន្តិសុខចំនួន២០០ផ្សេងទៀតដែល

ត្រូវបានរកឃើញ ហើយយើងក៏មិនបានដឹងអ្វីអំពីមន្ទីរស-២១ ថាតើ ឌុច ពិតជាបានទទួលបញ្ជា ឬក៏មានបំណងកម្ទេចឯកសារទាំងអស់នេះដោយខ្លួនឯងនោះទេ។

ចម្លើយសារភាពរបស់ ឌុច បានធ្វើឲ្យគាត់ខុសប្លែកពីសមាជិកនៃថ្នាក់ដឹកនាំខ្មែរក្រហមដទៃទៀត។ ប៉ុន្តែសំណួរចោទសួរថាតើ ឌុច នៅតែសារភាពដែលឬទេ ប្រសិនបើខ្លួនមិនបានបន្សល់ភស្តុតាងច្រើនបែបនេះ? ឌុច គឺជាគណិតវិទូ ដូច្នេះការសំអាងរបស់គាត់មានលក្ខណៈសមហេតុផល។ គាត់ទទួលស្គាល់ថាអ្វីៗទាំងអស់អាចរកបាននៅក្នុងឯកសារ។

គាត់និយាយដោយសាមញ្ញថា «ប្រសិនបើឯកសារពិតជាមានគ្រប់គ្រាន់មែននោះ ខ្ញុំមិនអាចបដិសេធបានឡើយ ហើយខ្ញុំទទួលស្គាល់តែភស្តុតាងណាដែលយកចេញពីមន្ទីរស-២១តែប៉ុណ្ណោះ»

កំហុសទីមួយរបស់ ឌុច គឺការមិនបានស្មានទុកជាមុននូវការឈ្លានពានយ៉ាងឆាប់រហ័សរបស់កងទ័ពវៀតណាមកាលពីដើមទសវត្សរ៍ឆ្នាំ១៩៧៩ និងកំហុសទីពីរ គឺគាត់មិនបានកម្ទេចចោលឯកសារទាំងអស់មុនពេលរកគេចខ្លួន។ ថ្នាក់លើរបស់ ឌុច ក៏បានបង្កើតកំហុស ដោយតែការអាកខានមិនបានបញ្ជាគាត់ឲ្យបំផ្លាញឯកសារទាំងនោះ។ តើពួកគេពិតជាមិនបានដឹងអំពីការរក្សាទុកឯកសារយ៉ាងដិតដល់ដោយឆ្មាំគុករបស់ខ្លួនទេឬ? តើ ឌុច ទុកចោលឯកសារទាំងអស់ដែលជាសមិទ្ធផលកើតចេញពីការខិតខំប្រឹងប្រែងរបស់ខ្លួនអស់រយៈពេលជាយូរ ពីព្រោះតែការប្រញាប់ប្រញាល់ពេក ឬការមិនបានស្មានទុកជាមុន? ឬក៏មកពី ឌុច មានមោទកភាពពេក មិនដាច់ចិត្តបំផ្លាញចោលការងារដ៏ល្អរបស់ខ្លួនខំធ្វើឡើងសម្រាប់បក្ស និងបដិវត្តន៍ ដែលការងារទាំងអស់នេះ គឺជាតឹកតាងនៃទេពកោសល្យ និងសមត្ថភាពរបស់ខ្លួនក្នុងការកសាងមន្ទីរសន្តិសុខដ៏ជោគជ័យ និងមានប្រសិទ្ធភាពមួយ?

ប្រសិនបើ ឌុច បានបំផ្លាញចោលឯកសារទាំងអស់របស់ខ្លួន យើងអាចនឹងមិនដឹងអ្វីច្រើនអំពីមន្ទីរស-២១ រួមទាំងទំហំនៃបទល្មើសដែលបានប្រព្រឹត្តិនៅក្នុងមន្ទីរសន្តិសុខនេះទេ។ យើងប្រហែលជាមិនអាចដឹងអំពីអត្តសញ្ញាណពិតប្រាកដរបស់ប្រធានមន្ទីរស-២១ ដែលត្រូវបានស្គាល់ថាជា«បងខាងកើត»ទេ។

អ្នករស់រានមានជីវិតមួយចំនួន អាចនឹងប្រាប់យើងអំពីកន្លែងដែលគួរឲ្យខ្លាចមួយនៅប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហម ។ តើមានគុកដែលមានអំពើសាហាវឃោរឃៅចំនួនប៉ុន្មានត្រូវបានលុបចោលពីទំព័រប្រវត្តិសាស្រ្តដោយសារតែគ្មានឯកសារសេសសល់? ប្រសិនបើគ្មានចម្លើយសារភាព រូបភាព ហើយនឹងជីវប្រវត្តិទេមន្ទីរស-២១ក៏ប្រហែលជាពុំមានដែរ ។ ជារួម មន្ទីរស-២១មាននៅថ្ងៃនេះ ដោយសារតែភាពមានមោទនភាពជ្រុលហួសហេតុ ឬការធ្វេសប្រហែសរបស់ថ្នាក់ដឹកនាំ ដោយមិនបំផ្លាញឯកសារការងាររបស់ឌុច ចោល ។

ឯកសារទាំងនោះមានគុណភាពល្អ និងមានលក្ខណៈហ្មត់ចត់ ។ បើគ្មានឯកសារទាំងអស់នេះទេ ប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យអាចពុំសូវមានលក្ខណៈពិស្តារ នឹងប្រហែលជាពិបាកយល់ ។ លោក ឆេនដល័រ បាននិយាយថា "ប្រសិនបើយើងមានឯកសារទាំងអស់នៅក្នុងរបបនេះ យើងប្រាដកជាមានប្រវត្តិសាស្រ្តរបបកម្ពុជាប្រជាធិបតេយ្យថ្មីមួយទៀត" ។ លោក ឆេនដល័រ បាននិយាយទៅកាន់តុលាការថាៈ

> *មន្ទីរស-២១ ប្រហែលជាមិនមានសារសំខាន់ (ចំពោះអង្គការ) ដូចចំពោះពួកយើងដែលកំពុងតែព្យាយាមរកភស្តុតាងទាក់ទិននឹងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ខ្ញុំគិតថា ប្រសិនបើយើងមានឯកសាររាល់អង្គប្រជុំនៃរបបនោះទាំងអស់ ខ្ញុំពិតជាភ្ញាក់ផ្អើល ប្រសិនបើមន្ទីរស-២១ត្រូវបានលើកឡើងមកពិភាក្សាជាញឹកញាប់ ។ ពិតប្រាដណាស់ មេដឹកនាំកំពូលៗចាប់អារម្មណ៍ចំពោះចម្លើយសារភាពរបស់អ្នកធ្លាប់មានតំណែងខ្ពស់ ប៉ុន្តែសម្រាប់សមាជិកបក្សទូទៅវិញ ពួកគេមិនចាប់អារម្មណ៍នោះទេ ។*

## ជំពូកទី១៧

ភាពពិតនៃបទពិសោធន៍នៃលទ្ធិផ្តាច់ការតែងតែស្ថិតនៅក្នុងភាពស្រអាប់ ។ នៅថ្ងៃនេះ ស្រ្តីជាសាក្សីម្នាក់បានមកបង្ហាញពីភាពស្មោះត្រង់ចំពោះបុរសជាប្តីដែលផ្សំផ្គុំដោយខ្មែរក្រហម ។ ប្តីរបស់គាត់គឺជាទាហាន

បដិវត្តន៍ និងត្រូវបានយកទៅសម្លាប់នៅមន្ទីរស-២១ កាលពីឆ្នាំ១៩៧៧ ។ សាក្សីបានរៀបរាប់ថា គាត់បានសម្រេចចិត្តចុះចូលជាមួយទ័ពព្រៃរបស់បក្សកុម្មុយនីស្តនៅឆ្នាំ១៩៧១ «ពីព្រោះខ្ញុំមានកំហឹងយ៉ាងខ្លាំងចំពោះទុក្ខវេទនាដែលយើងត្រូវទទួលរងក្រោមស្នាដៃរបស់ពួកចក្រពត្តិ និងមូលធននិយមអាមេរិក ។» ស្ត្រីរូបនោះបានចូលទៅក្នុងព្រៃម៉ាគី «ដើម្បីរំដោះប្រទេសជាតិពីពួកទាំងនោះ» ក្រោយមកគាត់បានក្លាយទៅជាមេបញ្ជាការកងអនុសេនាធំនៃកងទ័ពជ័យជម្នះរបស់របបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលដែលអង្គការបានរៀបចំពិធីរៀបការ គាត់ និងប្ដីរបស់គាត់ គឺជាគូរទីបីនៅក្នុងពិធីរៀបការដែលមានប្ដីប្រពន្ធច្រើនគូរៀបការដំណើរគ្នា ។ សម្រាប់ស្ត្រី ដែលពិបាកប្រារព្ធពិធីអបអរសាទរ ពីព្រោះខ្លួនរៀបការជាមួយបុរសមិនបានជ្រើសរើសដោយខ្លួនឯង អង្គការមានដំណោះស្រាយឲ្យ ៖ គឺគ្មានការរៀបចំពិធីអបអរអ្វីទាំងអស់ ។ ភាពសប្បាយរីករាយត្រូវបានចាត់ទុកជាការគាំទ្រវណ្ណៈមូលធន ។

ស្ត្រីម្នាក់នេះបាននិយាយថា « វាកើតឡើងឆាប់រហ័សពេក ។ »

> *នៅពេលព្រឹកព្រលឹម គេប្រាប់យើងថា ពិធីមង្គលការនឹងរៀបចំឡើងនៅវេលាម៉ោង ៧ថ្ងៃត្រង់ ។ ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើល ហើយបានសួរថា ហេតុអ្វីបានជាយើងត្រូវរៀបការលឿនម្ល៉េះ? តើឪពុកម្ដាយ ក្រុមគ្រួសារ និងអ្នកភូមិរបស់ខ្ញុំចូលរួមដែរឬទេ? ចម្លើយ គឺទេ ។ ខ្ញុំពិតជាមិនសប្បាយចិត្តចំពោះការរៀបចំពិធីមង្គលការនេះទេ ប៉ុន្តែពេលវេលាតម្រូវឲ្យយើងធ្វើដូច្នេះ ។ ពេលវេលាបានរៀបចំរួចជាស្រេច ហើយខ្ញុំមិនអាចបដិសេធបានឡើយ ។ គេក៏ប្រាប់ខ្ញុំថា យើងនៅក្នុងកងពិសេស ដូច្នេះយើងមិនត្រូវបានអនុញ្ញាតឲ្យរៀបការជាមួយអ្នកដែលនៅក្នុងកងផ្សេងនោះទេ ។ គេបានប្រាប់ខ្ញុំថា អង្គការប្រៀបដូចជាឪពុកម្ដាយរបស់យើង រៀបចំពិធីរៀបការឲ្យយើង ដូច្នេះយើងត្រូវតែទទួលការរៀបចំនេះ ។ ខ្ញុំមិនសប្បាយចិត្តយ៉ាងខ្លាំងនៅថ្ងៃដែលខ្ញុំរៀបការ ។*

មួយឆ្នាំក្រោយមក ប្តីរបស់គាត់ស្លាប់នៅមន្ទីរស-២១ ហើយរូបគាត់វិញត្រូវបានឲ្យទៅ "រៀនសូត្រឡើងវិញ" នៅមន្ទីរស-២៤ ។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានដួលរលំនៅក្នុងឆ្នាំ១៩៧៩ គាត់បានត្រលប់មកភូមិវិញ ហើយម្តាយរបស់គាត់បានប្រាប់គាត់ថា ព្រោះតែគាត់ជាអ្នកបដិវត្តន៍ ឪពុករបស់គាត់ត្រូវបានគេសម្លាប់ ។ គាត់បានលុតជង្គង់នៅចំពោះមុខម្តាយមីង និងអង្វរសុំការអត់ទោស ប៉ុន្តែម្តាយមីងរបស់គាត់បដិសេធ ។ ដូច្នេះ ថ្ងៃនេះ គាត់បាននិយាយថា គាត់សូមបដិសេធទាំងស្រុងចំពោះការសុំអភ័យទោសរបស់ ឌុច ដើម្បីបង្ហាញថា គាត់មិនមែនជាខ្មែរក្រហម គាត់ស្មោះត្រង់នឹងជាតិ ហើយគាត់"ត្រូវបានក្បត់ដោយក្រុមមួយនេះ" មានដូចជា ឌុច ។

ប្រសិនបើយើងសង្កេតមើលឲ្យបានវែងឆ្ងាយលើសពីការរំពឹងទុកអំពីការដាក់ទណ្ឌកម្មលើបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅមន្ទីរស-២១ យើងឃើញថាអ្វីៗទាំងអស់ដែលកើតឡើងនៅទីនោះ បានបំបែកបំបាក់ក្រុមគ្រួសារខ្មែរជាច្រើន ។ បន្ទុកយ៉ាងធ្ងន់ និងវិប្បដិសារីបានធ្លាក់ទៅលើក្រុមគ្រួសារដែលត្រូវបានចោទថាក្បត់ ។

ស្ត្រីម្នាក់ផ្សេងទៀតបានចូលខ្លួនមកធ្វើជាសាក្សី ។ គាត់ពាក់អាវស ហើយមានអាវធំខាងក្រៅពណ៌ទំពាំងបាយជូរ ស្លៀកសំពតសារុងមានពណ៌យ៉ាងស្រស់ប្រណិតបែបលក្ខណៈជាអ្នកទីក្រុង ។ សក់ស្កូវគាត់ត្រឹមកញ្ចឹងក ហើយចងទៅខាងក្រោយយ៉ាងមានសណ្តាប់ធ្នាប់ និងមានពាក់វ៉ែនតា គាត់មានអាយុ៧០ឆ្នាំ ប៉ុន្តែគាត់មើលទៅនៅក្មេង ហើយមានកម្លាំងមាំមួន ។ គាត់ក្តាប់ជាយអាវរបស់គាត់ និងទាញវាចុះក្នុងអាការៈភ័យខ្លាច ។ ជំនួយការរបស់ជនរងគ្រោះបានលើទឹកចិត្តដោយចាប់ដៃរបស់គាត់ ។ កាលពីជំនាន់របស់គាត់ មាននិស្សិតរាប់រយនាក់បានប្រលងជាប់ចូលរៀននៅសាលាពេទ្យ គាត់គឺជានិស្សិតស្រីម្នាក់ក្នុងចំណោមនិស្សិតស្រីតិចតួចដែលបានប្រលងជាប់ ប៉ុន្តែភ្លាមៗនោះគាត់និយាយសុំទោសថា "ពេលខ្លះខ្ញុំមានអារម្មណ៍ថា ខ្ញុំមានការភ្លេចភ្លាំងច្រើន" ។

គាត់និយាយយ៉ាងលឿន ។ នៅចំពោះមុខគាត់មានអត្ថបទកត់ត្រាសម្រាប់មើល ប៉ុន្តែគាត់មិនបានមើលវាទេ ។ នៅពេលគាត់ចាប់ផ្តើមនិយាយរៀបរាប់ពីរឿងរ៉ាវរបស់គាត់ គាត់លែងមានអារម្មណ៍ភ័យខ្លាច ។ គាត់រៀបរាប់ពីការជម្លៀសប្រជាជនរាប់រយនាក់ពីទីក្រុងភ្នំពេញក្នុងរយៈពេលតែប៉ុន្មានម៉ោងបន្ទាប់ពីខ្មែរក្រហមបានចូលមកដល់ក្នុងទីក្រុង ។ គាត់ចងចាំគ្រប់សកម្មភាពទាំងអស់ ។ គាត់នៅតែអាចធ្វើត្រាបតាមទាហានឈុតខ្មៅដែលនិយាយតាមមេក្រូថា អ្នកចេះដឹងទាំងអស់ត្រូវកម្ទេច ។ «ពួកគេនិយាយថាពួកគេទុកតែប្រជាជនមូលដ្ឋានតែប៉ុណ្ណោះ ។»

ប្តីរបស់គាត់ គឺជាអនុប្រធានអាកាសចរណ៍ស៊ីវិលនៅអាកាសយានដ្ឋានភ្នំពេញ ហើយត្រូវបានគេចាប់ខ្លួន ។ ចំណែករូបគាត់វិញត្រូវបានគេបញ្ជូនទៅ«រៀនសូត្រឡើងវិញ» ដោយធ្វើការនៅឯការដ្ឋានសាងសង់ទំនប់ទឹក ។ នៅរដូវវស្សា អ្នកគ្រប់គ្រងឈុតខ្មៅរបស់គាត់បានប្រាប់ថា បើគាត់អាចជម្នះការងារនេះ គាត់អាចមានរស់រានមានជីវិត ។ បើមិនដូច្នេះទេ គាត់នឹងត្រូវស្លាប់ ។ មុនពេលបន្តការរៀបរាប់បន្ថែមលើសោកនាដកម្ម និងព្រឹត្តការណ៍ដែលបានកើតឡើង គាត់បានបិទភ្នែកដើម្បីរំឭកនូវអតីតកាល ។ ចំណែកឯឌុច វិញក៏បានក្រោកឈរ និងស្តាប់យ៉ាងយកចិត្តទុកដាក់ ។

គាត់បានិយាយថា «ខ្ញុំរស់នៅដោយក្តីអស់សង្ឃឹមអស់រយៈយ៉ាងយូរ ទោះបីជាសេចក្តីស្លាប់មកដល់ខ្ញុំក៏មិនមានភាពភ័យខ្លាចដែរ ។»

បន្ទាប់ពីរបបនេះដួលរលំទៅ គាត់បានត្រឡប់មករស់នៅភ្នំពេញវិញ ហើយគាត់រកបានការងារនៅក្នុងមន្ទីរពេទ្យ ។ ថ្ងៃមួយ ចៅហ្វាយនាយរបស់គាត់បានហៅគាត់មកជួប ហើយបានប្រាប់គាត់ឲ្យទៅទស្សនាសារមន្ទីរស-២១ ។ គាត់ស្គាល់ច្បាស់ពីវិទ្យាល័យពញាយ៉ាត ដែលខ្មែរក្រហមបានប្តូរទៅជាកន្លែងអ្នកទោស ពីព្រោះមិត្តភក្តិឪពុកម្តាយរបស់គាត់ធ្លាប់រស់នៅជិតទីនោះ ។ គាត់និយាយថា គាត់បានជួបជាមួយនឹងអ្នកដែលរស់រានមានជីវិតម្នាក់ ពេលគាត់បានទៅដល់គុកនោះ ។ នៅចំពោះមុខអង្គជំនុំជម្រះនៅត្រង់ចំណុចនេះហើយ ដែលសម្តីរបស់គាត់បានបន្លឺឡើងយ៉ាងខ្លាំង ។ ការនិយាយរបស់គាត់មានលក្ខណៈ

ដាច់ៗ តែមានសម្រែកខ្លាំង ហើយគាត់និយាយទៅកាន់តុលាការក្នុងសូរសំឡេងមួយ ដែលនៅក្នុងភាសាខ្មែរ ច្រើនប្រើនៅពេលខឹងសម្បារ កើតទុក្ខ និងការមិនអាចយោគយល់បាន ។ នៅក្នុងមន្ទីរស-២១ គាត់ត្រូវបានគេបង្ហាញឯកសារខ្លះៗព្រមទាំងរូបថតផងដែរ ។ រូបថតចុងក្រោយ គឺជារូបប្តីរបស់គាត់ ដែលមានឈ្មោះថា ធិច ហួរ តុក ហៅ តុក ។ ឯកសារបានភ្ជាប់មកជាមួយថ្ងៃខែឆ្នាំដែលប្តីរបស់គាត់ត្រូវបានបញ្ជូនទៅមន្ទីរស-២១ៈ ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយគាត់ត្រូវបានសម្លាប់នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៦ ។

នៅក្នុងរូបថត ក្រសែភ្នែកដ៏មុតរបស់ប្តីគាត់ហាក់បីដូចជាផ្តើនអ្នកថតរូប ។ ប្តីរបស់គាត់នៅក្នុងរូបថតមានពុកមាត់ និងពុកចង្កា ប៉ុន្តែមិនសូវក្រាស់ទេ ។ ភ្នែករបស់គាត់មើលទៅដូចជាស្រលៀងបន្តិច ។ តុក បានខាំមាត់របស់គាត់ ដែលធ្វើឲ្យគាត់មើលទៅដូចមានការងឿងឆ្ងល់ ។ ចំណែកឯបងប្រុសគាត់ដែលអ្នកជាបើកយន្តហោះ ក៏ត្រូវបានកម្ទេចចោលនៅមន្ទីរស-២១ដែរ ។ ស្ត្រីមេម៉ាយរូបនេះបានទម្លាក់សំឡេងបន្តិចវិញ ដើម្បីបង្ហាញអំពីការសន្ទនារបស់គាត់ជាមួយបងប្អូនជីដូនមួយ និងក្មួយស្រីរបស់គាត់ ជូនដល់តុលាការ ។ ពេលខ្លះគាត់ហាក់បីដូចជាមានការវង្វេងវង្វាន់ស្មារតី ហើយមានការភាន់ច្រឡំ ប្រហែលជាគាត់មានជំងឺផ្លូវចិត្ត ដូចដែលគាត់និយាយមុនពេលចាប់ផ្តើមសក្ខីកម្មនេះ ។ គាត់បន្តទៀតថា របបនេះចោទប្រកាន់ប្តីរបស់គាត់ថាបានប្រព្រឹត្តបទឧក្រិដ្ឋដ៍ធំមួយ ។ ហើយភ្លាមៗនោះ សំឡេងខឹងក្រោតរបស់គាត់បានបន្លឺឡើងនៅក្នុងបន្ទប់សវនាការដោយសួរសំណួរដដែលៗថា “ហេតុអ្វី? ហេតុអ្វី? ហេតុអ្វី? ”

គាត់បាននិយាយថា មនុស្សមានពីរប្រភេទ ប្រភេទទីមួយ គឺអ្នកដែលមានរូបរាងដូចមនុស្សលោកទូទៅ ហើយមានចិត្តល្អ ប៉ុន្តែប្រភេទទីពីរ គឺជាអ្នកដែលមានរូបរាងជាមនុស្សលោកដែរតែមានចិត្តដូចជាសត្វតិរច្ឆាន ។ ស្ត្រីដែលមានជំនឿយ៉ាងមុតមាំលើសាសនាម្នាក់នេះ បានបួងសួងឲ្យ ឌុច ថា នៅជាតិក្រោយ “សូមកុំឲ្យមានភាពកាចសាហាវដូចជាមនុស្សរបស់ ប៉ុល ពត ទៀត ។” បន្ទាប់មក គាត់ក៏សួរសំណួរដដែលថាៈ ហេតុអ្វី?

«ហេតុអ្វីបានជាមនុស្ស ដែលមិនបានធ្វើអ្វីខុសសោះត្រូវបានគេយកទៅដាក់គុក និងធ្វើបាបដូច្នេះ? ខ្ញុំមិនយល់ទាល់តែសោះ ។»

គាត់មិនបានចាំផ្នែកខ្លះនៃរឿងរ៉ាវដែលបានកើតឡើងចំពោះគាត់ នៅពេលដែលគាត់ព្យាយាមចង ចាំអំពីរឿងរ៉ាវទាំងអស់នេះ អារម្មណ៍របស់គាត់មានការវិលវល់ ។ អ្វីដែលគាត់អាចចាំបាន គឺខ្មែរក្រហម បានមកចាប់ប្តីគាត់ ប្តីរបស់គាត់បាត់ខ្លួន ហើយប្តីរបស់គាត់ត្រូវបានសម្លាប់ ។ អ្វីទាំងអស់នេះ គឺពិតជា គ្រប់គ្រាន់ដែលអាចធ្វើឲ្យយើងមានការខឹងសម្បារ ។

លោកប្រធានចៅក្រមបាននិយាយថា «នេះគឺជាពេលវេលាដែលសមល្មមនឹងសម្រាក ។»

ជាការពិត បងស្រីរបស់សាក្សីម្នាក់នេះ គឺជាអ្នករាយការណ៍ប្រាប់ពីរឿងរបស់ប្តីគាត់ទៅឲ្យអ្នក យាមឈុតខ្មៅ ។ ចំពោះសាក្សីផ្ទាល់ បងស្រីរបស់គាត់ប្រៀបដូចជាម្តាយរបស់គាត់ ។

> យើងមានអារម្មណ៍ថាត្រូវបានគេក្បត់ ។ បងស្រីរបស់ខ្ញុំត្រូវបានបញ្ចុះបញ្ចូលឲ្យដើរ តាមរបបគេ ដូច្នេះហើយបានជាគាត់និយាយនូវអ្វីដែលគាត់បាននិយាយ ។ បន្ទាប់ ពីអ្វីគ្រប់យ៉ាងបានកើតឡើង និងវេទនាក្នុងវេទនាអស់រយៈយ៉ាងយូរ ខ្ញុំបានសួរគាត់ថាលទ្ធិ កុម្មុយនីស្តពិតប្រាកដជាអ្វី? ឥឡូវខ្ញុំបានដឹងហើយថាវាជាអ្វី វាគឺជាការប្រចណ្ឌ ការប្រកួតប្រជែង ឃាតកម្ម ការបញ្ជូនមនុស្សទៅសម្លាប់មន្ទីរស-២១ ការក្បត់ ការរាយការណ៍ពីបងប្អូនឯង ហើយវាគឺជារបបមួយដែលមនុស្សដែលយើងស្រឡាញ់ ត្រូវបានចាប់ខ្លួន និងសម្លាប់ ។ នៅពេលដែលខ្ញុំគិតដល់ធម៌របស់ព្រះពុទ្ធ ខ្ញុំបានរំងាប់ អារម្មណ៍ ហើយខ្ញុំយល់ថាអ្វីដែលគាត់បានធ្វើ ពីព្រោះលទ្ធិកុម្មុយនីស្តបានបញ្ចុះបញ្ចូល ឲ្យគាត់ប្តូរគំនិត ។ គាត់បានរាយការណ៍ពីប្តីរបស់ខ្ញុំ ហើយខ្ញុំបានស្តីបន្ទោសគាត់ ប៉ុន្តែ ប្រហែលជាគាត់ចង់ក្លាយជាប្រពន្ធរបស់ ប៉ុល ពត ។ គាត់នឹងទទួលវេរកម្មចំពោះអ្វី ដែលគាត់បានធ្វើ ។

ចៅក្រមទាំងអស់មានសភាពស្ងៀមស្ងាត់ ។ មេធាវីរបស់គាត់មិនបាននិយាយអ្វីទាំងអស់ ដោយឲ្យគាត់រៀបរាប់ពីទុក្ខវេទនារបស់គាត់តាមចិត្ត ។ មេធាវីក៏មិនសួរសំណួរទៅគាត់ដែរ ហើយគ្មាននរណាម្នាក់នៅក្នុងអង្គតុលាការហ៊ានបង្អាក់នូវការរៀបរាប់ ការឈឺចាប់ ការខឹងក្រោធ និងការសួរសំណួរដដែល គឺហេតុអ្វី? ហើយសំណួរដែលគ្មានចម្លើយនេះនៅតែដក់ក្នុងចិត្តរបស់គាត់ ។ «ខ្ញុំស្មោះត្រង់ចំពោះប្រទេសរបស់ខ្ញុំ ហើយខ្ញុំក៏ស្មោះត្រង់ចំពោះប្តីរបស់ខ្ញុំដែរ ។ ហេតុអ្វីបានជាទារុណកម្មនេះធ្លាក់មកលើរូបខ្ញុំដូច្នេះទៅវិញ?»